# ឯកឧត្តម ចម ប្រសិទ្ធ ជួបលោកជំទាវឯកអគ្គរដ្ឋទូតសិង្ហបុរី និងឯកឧត្តម

# ឯកអគ្គរដ្ឋទូតកូរ៉េ ខាងត្បូង ដែលចប់អណត្តិ នៅកម្ពុជា

នៅរសៀលថ្ងៃ ១៦ ខែ សីហា ឆ្នាំ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានទទួលជួបលោកជំទាវ **TAN Yee Woan** ឯកអគ្គរដ្ឋទូតសិង្ហបុរី ប្រចាំកម្ពុជា ដើម្បីសំដែងការគួរសម និងជំរាបលា ក្នុងឱកាសដែលលោកជំទាវ ត្រូវបានបញ្ចប់អណត្តិការទូតរយៈពេល០៣ ឆ្នាំនៅកម្ពុជា ។

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានវាយតំលៃខ្ពស់ ចំពោះទំនាក់ទំនងការទូត ដ៏ល្អរវាងកម្ពុជា និង សិង្ហបុរី ទាំងលក្ខណៈទ្វេភាគី និងក្របខ័ណ្ឌតំបន់ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណ ដល់ប្រទេស សិង្ហបុរីដែលជារៀងដ៏រាបមក បានជួយជំនួយបច្ចេកទេសទាក់ទងនិងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ដូចជាៈកសាងផ្នែកគោលនយោបាយពាណិជ្ជកម្មជាដើម ។

លោកជំទាវ **TAN Yee Woan** ឯកអគ្គរដ្ឋទូតសិង្ហបុរី ប្រចាំកម្ពុជា បានសំដែងនូវការពេញចិត្ត ចំពោះការបំពេញបេសកកម្មកាទូត នៅកម្ពុជា ដែលធ្វើឱ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ កាន់តែត្រូវបានពង្រឹងពង្រីកឥតឈប់ឈរ ។ ជាមួយគ្នានេះ លោកជំទាវក៏បានវាយតំលៃខ្ពស់ ចំពោះយុទ្ធសាស្ត្ររាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញនូវគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលនឹងធ្វើឱ្យកម្ពុជា ក្លាយជាប្រទេសផ្គត់ផ្គង់អង្ករដ៏ធំមួយលើសកលលោក ហើយប្រទេសសិង្ហបុរីក៏ជាអតិថិជនទិញអង្ករពីកម្ពុជាផងដែរ ។

ដោយឡែក នៅរសៀលថ្ងៃដដែល ឯកឧត្តមទេសទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានទទួលជួបឯកឧត្តម Lee Kyung-Soo ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំកម្ពុជា ដើម្បីសំដែងការគួរសម និងជំរាបលា ក្នុងឱកាសដែលឯកឧត្តមត្រូវបានបញ្ចប់អណត្តិការទូតនៅកម្ពុជា ។

ឯកឧត្តម ឯកអគ្គរដ្ឋទូតកូរ៉េខាងត្បូង បានបង្ហាញនូវមនោសញ្ចេតនាថាៈ រយៈពេល ០៣ ឆ្នាំ នៃការបំពេញបេសកម្មការទូតនៅកម្ពុជា ហាក់ដូចជា ជាឆាប់ណាស់សំរាប់ឯកឧត្តម ។ ឯកឧត្តម បានធ្វើការកត់សំគាល់ពីទំនាក់ទំនង មិត្តភាព និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរក្នុងលក្ខណៈដ៏ប្រសើរ។ ក្នុងនោះ តាមរយៈទំនាក់ទំនងដ៏ល្អប្រពៃនេះ កម្ពុជា-សាធារណរដ្ឋកូរ៉េ បានចុះកិច្ចព្រមព្រៀង និងអនុស្សារណៈយោគយល់គ្នាជាច្រើន ដែលមានតំលៃទៅដល់ការផ្លាស់ប្តូរពាណិជ្ជកម្ម និងជំនួយអភិវឌ្ឍន៍ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីទំនាក់ទំនងជាប្រវត្តិសាស្ត្រដ៏ប្រពៃ រវាងប្រទេសទាំងពីរកម្ពុជា-កូរ៉េ និងថ្លែងអំណរគុណដល់ប្រទេសកូរ៉េ ដែលបានជួយជំនួយឧបត្ថម្ភដល់កម្ពុជា ដូចជាៈជំនួយបច្ចេកទេស-ជំនួយអភិវឌ្ឍន៍-ការបណ្តុះបណ្តាលធនធានមនុស្ស និងការកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាដើម ។ ជាក់ស្តែង ប្រទេសកូរ៉េកំពុងដំណើរការកសាងជួសជុលផ្លូវជាតិលេខ៣ សំរាប់សំរួលការធ្វើដំណើរ ពីភ្នំពេញទៅខេត្តកំពត ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានថ្លៃអំណរគុណដល់ប្រទេសកូរ៉េ ដែលបានផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មនូវមុខទំនិញ ៧៨ មុខដល់កម្ពុជា ។ ជាមួយគ្នានេះដែរ ឯកឧត្តមក៏បានស្នើំឱ្យប្រទេសកូរ៉េ ជួយបង្កលក្ខណៈងាយស្រួលដល់កម្ពុជាក្នុងការទៅចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ដែលនឹងប្រារព្ធធ្វើនៅសាធារណរដ្ឋកូរ៉េនៅឆ្នាំ ២០១២ ខាងមុខនេះ ។